ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១១-១១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៤០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះអស់លោក និងលោកស្រី ចំនួន ១៨ រូប ១០៧០៦

២២-១១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៧៨ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក ស៊ូ យ៉ុងស៊ី (XU RONGXI) ជនជាតិចិន សញ្ជាតិចិន កើតនៅ ខេត្តយូណាន សាធារណរដ្ឋប្រជាមានិតចិន ១០៧០៨

២២-១១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៧៩ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក ខន់រ៉ាដ ស្វាហ្សស៍ (KONRAD SCHWARZ) ជនជាតិស្វីស សញ្ជាតិស្វីស កើតនៅ ទីក្រុងស៊ូរីក សហព័ន្ធស្វីស ១០៧០៩

២២-១១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៨០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះសប្បុរសជន ចំនួន ០២ រូប ១០៧១០

២២-១១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៨១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម លោកជំទាវ អស់លោក និងលោកស្រី ចំនួន ២២ រូប ១០៧១១

២២-១១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៨២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះមន្ត្រីរាជការ និងសប្បុរសជន ចំនួន ២៦ រូប ១០៧១៣

២២-១១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៨៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះព្រះសង្ឃ ឯកឧត្តម លោកជំទាវ ឧបាសក អស់លោក និងលោកស្រី ចំនួន ០៨ រូប ១០៧១៥

២២-១១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៨៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះលោក និងលោកស្រី ចំនួន ០២ រូប ១០៧១៦

២២-១១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៨៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សហមេត្រីចំពោះឯកឧត្តម **Joachim Baron Von Marschall** ១០៧១៧

២២-១១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៨៦ ស្តីពី ការកាត់ផ្ទៃដីទំហំ ២៩៤,៨៨ ហិកតា ចេញពីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ៨ ១០៧១៨

២២-១១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៨៧ ស្តីពី ការកាត់ផ្ទៃដីទំហំ ៥.៧៤ ហិកតា ចេញពីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ៨ ១០៧១៩

២២-១១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៨៨ ស្តីពី ការកាត់ផ្ទៃដីទំហំ ៤.៤៤ ហិកតា ចេញពីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ៨ ១០៧២០

២២-១១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៨៩ ស្តីពី ការតែងតាំង លោកស្រី ឈរ សៀកហ៊ួយ ជា ឧកញ៉ា ១០៧២១

២២-១១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៩០ ស្តីពី ការតែងតាំង ឯកឧត្តម យូ ស៊ូយ៉ិខ ជា ឧកញ៉ា ១០៧២២

២៣-១១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៩១ ស្តីពី ការកែសម្រួលសមាសភាពក្រុមប្រឹក្សា គណៈស្ថាបត្យករកម្ពុជា និងអគ្គលេខាធិការដ្ឋាននៃគណៈស្ថាបត្យករកម្ពុជា ១០៧២៣

២៣-១១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៩២ ស្តីពី ការតែងតាំង ឯកឧត្តម ឡុង សារពន្ធុ ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិ ទន្លេមេគង្គ មានឋានៈស្មើ អគ្គនាយក ១០៧២៦

២៣-១១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៩៣ ស្តីពី ការតែងតាំងទីប្រឹក្សាអមទីស្តីការ គណៈរដ្ឋមន្ត្រី ចំនួន ០២ រូប ១០៧២៧

២៣-១១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៩៤ ស្តីពី ការតែងតាំង មន្ត្រីរាជការ ចំនួន ០៣ រូប ជាទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើ អគ្គនាយក ១០៧២៨

## II-រាជរដ្ឋាភិបាល

## អនុក្រឹត្យ

០៤-១២-២០១៣-អនុក្រឹត្យលេខ ៥៥៩ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៨៨៦.៨៩ ហិកតា នៅស្រុក ថ្មពួក ខេត្តបន្ទាយមានជ័យ ចេញពីដីតម្រូបព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដី ឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៩០ គ្រួសារ និងរក្សា ទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ១០៧២៩

*-អនុក្រឹត្យលេខ ៥៦០,៥៦១ អនក្រ.បក មិនទាន់បានទទួល*

១១-១២-២០១៣-អនុក្រឹត្យលេខ ៥៦២ អនក្រ.បក ស្តីពី ការកែសម្រួលអត្រាអាករពិសេសលើទំនិញ មួយចំនួន ១០៧៣៣

១៨-១២-២០១៣ -អនុក្រឹត្យលេខ ៥៦៣ អនក្រ.បក ស្តីពី ការធ្វើចំណាត់ថ្នាក់ជាទ្រព្យសម្បត្តិរបស់រដ្ឋ នូវទីតាំងដីសម្រាប់ការសាងសង់អគារត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិព្រៃវល្លិ៍ ១០៧៣៧
២០-១២-២០១៣ -អនុក្រឹត្យលេខ ៥៦៤ អនក្រ.បក ស្តីពី ការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិ តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ ១០៧៤១
២០-១២-២០១៣ -អនុក្រឹត្យលេខ ៥៦៥ អនក្រ.បក ស្តីពី ការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិ តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ ១០៧៤៩
១១-១២-២០១៣ -អនុក្រឹត្យលេខ ១១៦៣ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១០៧៧០

## III-ការងារបណ្តាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

០៣-១២-២០១៣ -សារាចរណែនាំលេខ ០០៤ សហវ. ស្តីពី ការបិទបញ្ជីចំណូល ចំណាយ និងធ្វើរបាយការណ៍បូកសរុបទូទាត់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ ២០១៣ ១០៧៩៨
០៧-១១-២០១៣ -ប្រកាសលេខ ១១១៦ សហវ. ស្តីពី ការបង្វែរឥណទានជូនរាជធានីភ្នំពេញ សម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១៣ ១០៨០១
០៨-១១-២០១៣ -ប្រកាសលេខ ១១១៧ សហវ. ស្តីពី ការធ្វើនិយ័តកម្មឥណទានថវិកា ១០៨០៦
០៨-១១-២០១៣ -ប្រកាសលេខ ១១១៨ សហវ. ស្តីពី ការធ្វើនិយ័តកម្មឥណទានថវិកា ១០៨០៨
០៨-១១-២០១៣ -ប្រកាសលេខ ១១១៩ សហវ. ស្តីពី ការបង្វែរឥណទានជូនរដ្ឋបាលក្រុង ស្រុក នៃខេត្តកោះកុង សម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១៣ ១០៨១០

### ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

១៥-១១-២០១៣ -ប្រកាសលេខ ៩២៥ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ី.អេ.អូ.អ៊ីមផត អិចផត សឺវិស បង្កើតរោងចក្រផលិត សម្លៀកបំពាក់ ១០៨១៤
១៥-១១-២០១៣ -ប្រកាសលេខ ៩២៦ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន តាន បៀវន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ បង្កើតរោងចក្រផលិត ជ័រកៅស៊ូ ១០៨១៨
១៥-១១-២០១៣ -ប្រកាសលេខ ៩២៧ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ប្រ៊្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី បង្កើតរោងចក្រផលិត សម្លៀកបំពាក់ ១០៨២២

# ព្រះរាជក្រឹត្យ

នស/រកត/១២១៣/១២៤០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

*យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាធម្មពោធិសាល*
*ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា*

*ប្រោសព្រះរាជទាន*

*នូវ*

*ក/ គ្រឿងឥស្សរិយយស* **សហមេត្រី** *ថ្នាក់* **ធិបឌិន្ទ** :

- *លោក* ZHOU YOU
- *លោក* HE SILI
- *លោកស្រី* MA ZHIYUN

*ខ/ គ្រឿងឥស្សរិយយស***សហមេត្រី** *ថ្នាក់* **សេនា** :

- *លោក* QIU CHUANGXING
- *លោក* ZHANG FENGDONG
- *លោក* LIANG XINDA
- *លោក* ZOU GEN
- *លោក* WANG CAIWEN
- *លោក* HUANG SHUIGEN
- *លោក* LIU HUAXING
- *លោក* HUANG JIANJUN

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

| | | |
|---|---|---|
| -លោក | XIN | YUANXIN |
| -លោក | XIN | YUANLIANG |
| -លោក | WANG | KECHENG |
| -លោក | DOU | XIAOCHUN |
| -លោក | SHENG | HUI |
| -លោក | YIN ZHI | XIANG |

គ/ គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** :

-លោក អ៊ុន ចំណាន

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចារលេខ ១៣១១.១២៥៤

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០១៣

លេខៈ១៣៦៣ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៧៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ស៊ី យ៉ុងស៊ី** (XU RONGXI) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៥៧ នៅខេត្តយូណាន សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧ គស.១៣១១.១២៩២

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខ:១២៧៦ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៧៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ខនរ៉ាដ ស្វាហ្សស៍** (KONRAD SCHWARZ) ជនជាតិស្វីស សញ្ជាតិស្វីស កើតថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៧២ នៅទីក្រុងស៊ូរីក សហព័ន្ធស្វីស។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរកត. ១៣១១. ១២៩៣

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខ:១២៧៥ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៨០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា**
**សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា )

## ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន ០២រូប ដែលមានស្នាដៃល្អ
និងគុណបំណាច់ធំៗជាច្រើន ក្នុងការចូលរួមចំណែកកសាង អភិវឌ្ឍន៍ប្រទេសជាតិ

នូវ

គ្រឿងឥស្សរិយយស **ជាតូបការ** :

១- ឯកឧត្តមឧត្តមសេនីយ៍ឯក **ហ្វូ ឫទ្ធី**

២- ឯកឧត្តម **ម៉ែន ទិបុល**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល. ១៣១១.១២៥៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខ: ១២៦០ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៥១

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

## ប្រោសព្រះរាជទាន

## ដល់

ក-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានីព្រះស៊ីសុវត្ថិមុនីវង្សកុសុមៈនារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-លោកជំទាវ ញ៉ែម សាខន ស ខេង ២-លោកជំទាវ នុត យ៉េង ស ចេង
៣-លោកជំទាវ យូ ឈីម ៤-លោកស្រី ស៊ុំ ចាន់ធូ

ខ-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានីព្រះស៊ីសុវត្ថិមុនីវង្សកុសុមៈនារីរ័ត្ន ថ្នាក់ មហាសេនា :

១-លោកស្រី ស ស៊ិន ២-លោកស្រី ស លន់
៣-លោកជំទាវ ស ចេង

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :

១-ឯកឧត្តម តេជ្រ៍ សុនិទា ២-លោកឧត្តមសេនីយ៍ត្រី ម៉ាន់ សារឿន
៣-លោកវរសេនីយ៍ឯក ស៊ូ ម៉ារាឌី ៥-ឯកឧត្តម យ៉ឹម ខេង
៦-លោក ហួន ណាត

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •
ក្រសួងព្រះបរមរាជវាំង

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

១-លោក ឌួន សុគន្ធា ២-លោក ជា សួរ

៣-លោកអនុសេនីយ៍ឯក លាង សារិទ្ធ

ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់សេនា :

១-លោក ខិន សុខុម ២-លោក រស់ គឹមហេង

៣-លោកវរសេនីយ៍ត្រី ថន ឌួច ៤-លោកអនុសេនីយ៍ឯក សំ សាម៉ុឌី

ច-គ្រឿងឥស្សរិយយសស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់អស្សឫទ្ធិ :

លោកអនុសេនីយ៍ត្រី សៀង សារឹន

ឆ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់មហាសេរីវឌ្ឍន៍ :

ឧបាសក រស់ ឈុន

ជ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់មហាសេនា :

១-លោកឧត្តមសេនីយ៍ត្រី ព្រាប ធុន្ធី ២-លោក ថន ជា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស.រកត.១១១៣.១២៩៥

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០១៣

លេខ:១២៧៥ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ .ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៨២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

## ប្រោសព្រះរាជទាន

ចំពោះមន្ត្រីរាជការ និងសប្បុរសជន ចំនួន ២៦រូប ដែលមានស្នាដៃល្អ
និងគុណបំណាច់ជាច្រើនក្នុងការបម្រើជាតិមាតុភូមិ

**នូវ**

ក- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១-លោក **មួង ថាយ** ២-លោក **ញ៉ៅ លីយ៉ុង**

ខ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១-លោក **អ៊ុង ខាន់ណារិទ្ធ** ២-លោក **អ៊ុកចន្ទ្រ ឡុងវី**

៣-លោក **ថេង កន្ធុំ**

គ-គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេនា** :

១-លោក **ហឿន ឌឿ** ២-លោក **អ៊ុក ទុឡារិទ្ធ**

៣-លោក **កែវ សុផាន** ៤-លោក **អ៊ុង ភាណារ៉ែន**

៥-លោក **សុខ ចាន់ណាវុធ** ៦-លោក **ខាន់ វាសនា**

ឃ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** :

១-លោក **សុន ម៉ានិត** ២-លោក **អ៊ុក ដាវ៉ាន់ឌី**

៣-លោក **ឆុន សុភាព** ៤-លោក **ឈួយ វណ្ណៈ**

៥-លោក **មឿន ចាន់លី** ៦-វេជ្ជបណ្ឌិត **អ៊ុយ គីណា**

ង- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** :

១-លោក **លីម ស៊ាងគ្រី** ២-លោក **ម៉ោញ សាយ័ន្តសុម៉ាលី**

៣-លោក **មាស សន្តិភាព** ៤-លោក **ឌួន ផាន់ណា**

៥-លោក **ហង្ស សុផាតតីរម្យ**

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ច- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ សេនា :

-លោក **គិត ចាន់ថន**

ឆ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ អស្សឫទ្ធិ :

១-លោក **សែន សំអឿន** ២-លោក **ទ៉ា ទ៉ាន់សាក់**

៣-លោក **អ៊ុំ សំណាង**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ចរស ១៣១១.១២៩៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៣

លេខ:១២៧៣ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ,ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៤៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

**នូវ**

**គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :**

| | |
|---|---|
| ១-ព្រះតេជគុណនេតុបណ្ឌិតោ **គៀន ប៊ុច** | ២-ឯកឧត្តម **មុំ ក្រោត** |
| ៣-លោកជំទាវ **គីម ហាន សេង វ៉ាឡាត់** | ៤-លោកស្រី **អ៊ឹម ចំឡងចន** |
| ៥-លោក **ស្រី ថៃសេង** | ៦-ឧបាសក **សៅរ៍ សាម៉ីន** |
| ៧-ឧបាសិកា **ក្រាំ អាំងគីម** | ៨-លោកស្រី **សោ ថាលី** |

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស.១៣១១.១២៩៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១៣

លេខ:១២៧២ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៩៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្នត្តយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

**ប្រោសព្រះរាជទាន**

**ដល់**

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍**
**លោក មាស ឆាយ**

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា**
**លោកស្រី ឆួន សុខពៅ**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរល.១៣១១.១២៩៤

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខ:១២៦៧/ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៨៥

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

**ប្រោសព្រះរាជទាន**

**ចំពោះ**

**ឯកឧត្តម Joachim Baron Von Marschall**

**នូវ**

**គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣វល. ១៣១១.១២៩៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខៈ ១២៧១ស.ណ
**សំណៅចែលមានគន្លែងការចែកផ្សាយ**
រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៩៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្មូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានកាត់ផ្ទៃដីទំហំ ២៩៩,៤៨ ហិកតា ចេញពីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ៨ ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចារស.១៣១១.១៣០០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ២០១៣

លេខៈ១២៧០ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៨៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានកាត់ផ្ទៃដីទំហំ ៥,៧៨ ហិកតា ចេញពីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ៨ ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានឃើញ ១៣១១.១៣០១

លេខ: ១២៦៩ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ២០១៣

រាជធានីភ្នំពេញ ,ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៩៩

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១**: ត្រូវបានកាត់ផ្ទៃដីទំហំ ៩,៨៩ ហិកតា ចេញពីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ៨ ។

**មាត្រា ២**: សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧រស. ១៣១១. ១៣០២

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខ:១២៦៩ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៥៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ប្រធានព្រឹទ្ធសភា)

## ត្រាស់បង្គាប់

តែងតាំង :

លោកស្រី ឈរ សៀកហ៊ួយ

ជា

ឧកញ៉ា

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល. ១៣១១. ១៣០៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខ:១២៨៤ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៩០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ប្រធានព្រឹទ្ធសភា)

**ត្រាស់បង្គាប់**

**តែងតាំង :**

**ឯកឧត្តម យូ ស៊ុយហ៊ីង**

**ជា**

**ឧកញ៉ា**

ពរស. ១៣១១.១៣០៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខ: ១២៨៥ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១៤៩១

## ស្តីពី
## ការកែសម្រួលសមាសភាពក្រុមប្រឹក្សាគណៈស្ថាបត្យករកម្ពុជា
## និងអគ្គលេខាធិការដ្ឋាននៃគណៈស្ថាបត្យករកម្ពុជា

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សម្មានភូមិ ជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១១/១១២៤ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១១ ស្តីពីការបង្កើតគណៈស្ថាបត្យករកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២១២/០៥៨ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២ ស្តីពីការកំណត់សមាសភាពក្រុមប្រឹក្សាគណៈស្ថាបត្យករកម្ពុជា និងតែងតាំងសមាសភាពអគ្គលេខាធិការដ្ឋាននៃគណៈស្ថាបត្យករកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** ត្រូវបានកែសម្រួលសមាសភាពក្រុមប្រឹក្សាគណៈស្ថាបត្យករកម្ពុជា :

- សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ប្រធានកិត្តិយស

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **អ៊ឹម ឈុនលឹម** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ប្រធាន |
| ២- ឯកឧត្តម | **ហង់ ជួនណារ៉ុន** | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៣- លោកជំទាវ | **ភឿង សកុណា** | រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៤- ឯកឧត្តម | **ត្រាំ អ៊ីវតឹក** | រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| ៥- ឯកឧត្តម | **រស់ ប៊ុនរ៉ាត** | ប្រធានគណៈកម្មាធិការជាតិបេតិកភណ្ឌពិភពលោក | អនុប្រធាន |
| ៦- ឧកញ៉ា | **គិត ម៉េង** | ប្រធានសភាពាណិជ្ជកម្មកម្ពុជា | សមាជិក |
| ៧- ឧកញ៉ា | **ពុង ឃាវសែ** | ប្រធានសមាគមអ្នកសាងសង់កម្ពុជា | សមាជិក |
| ៨- ឯកឧត្តម | **ភឿង សុភ័ណ្ឌ** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន | សមាជិកអចិន្ត្រៃយ៍ |
| ៩- ឯកឧត្តម | **អ៊ិត ប្រាំង** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១០-ឯកឧត្តម | **សួស គង់** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១១-ឯកឧត្តម | **ម៉ែន សុផល** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១២-ឯកឧត្តម | **ប៉ាន សូរស័ក្តិ** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៣-ឯកឧត្តម | **ឃិន គិមស៊ាន** | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១៤-លោកជំទាវ | **គង់ បញ្ញា** | រដ្ឋលេខាធិការក្រសួងព្រះបរមរាជវាំង | សមាជិក |
| ១៥-ឯកឧត្តម | **អ៊ិន ធីរជាតិ** | ប្រធានក្រុមប្រឹក្សាភិបាលសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា | សមាជិក |
| ១៦-ឯកឧត្តម | **អ៊ុំ ប៊ុនធឿន** | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ១៧-ឯកឧត្តម | **ច័ន្ទ សំណាង** | អនុប្រធានរាជបណ្ឌិតសភាកម្ពុជា | សមាជិក |
| ១៨-ឯកឧត្តម | **ម៉ម សុធារ៉ា** | ទីប្រឹក្សាក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៩-ឯកឧត្តម | **លី យុទ្ធត្រៃ** | សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | សមាជិក |
| ២០-ឯកឧត្តម | **ដេត ដាលី** | សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ២១-ឯកឧត្តម | **ប៊ុច សុវត្ថិ** | សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ | សមាជិក |
| ២២-ឯកឧត្តម | **អ៊ុម ម៉ឿនី** | នាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | សមាជិក |
| ២៣-ឯកឧត្តម | **អ៊ិច សេង** | សាកលវិទ្យាធិការនៃសាកលវិទ្យាល័យមេគង្គកម្ពុជា | សមាជិក |
| ២៤-លោក | **លឹម ធីរត្ន** | ប្រធាននាយកដ្ឋានក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ២៥-លោក | **ចាន់ សុឃាង** | សាកលវិទ្យាធិការនៃសាកលវិទ្យាល័យន័រតុន | សមាជិក |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

២៦-លោក **ឡៅ សីហា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យបៀលប្រាយ សមាជិក

**មាត្រា២:** ត្រូវបានកែសម្រួលសមាសភាពអគ្គលេខាធិការដ្ឋាននៃគណៈស្ថាបត្យករកម្ពុជា :

១-ឯកឧត្តម **តឿង សុវណ្ណា** អគ្គលេខាធិការ មានឋានៈស្មើរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

២-ឯកឧត្តម **ហ៊ុយ ណារ៉ា** អគ្គលេខាធិការរង មានឋានៈស្មើរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

៣-ឯកឧត្តម **ឌី ស៊ីថា** អគ្គលេខាធិការរង មានឋានៈស្មើអនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

៤-ឯកឧត្តម **ឆាយ ឫទ្ធិសែន** អគ្គលេខាធិការរង មានឋានៈស្មើអនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

៥-ឯកឧត្តម **ញ៉ន ស៊ី** អគ្គលេខាធិការរង មានឋានៈស្មើអនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

៦-ឯកឧត្តម **បេងហុង សុជាតិខេមរ៉ូ** អគ្គលេខាធិការរង មានឋានៈស្មើអនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

៧-ឯកឧត្តម **ម៉េង ម៉ុណ្ណារិទ្ធ** អគ្គលេខាធិការរង មានឋានៈស្មើអនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

៨-ឯកឧត្តម **ឡៅ និច្ចសីហា** អគ្គលេខាធិការរង មានឋានៈស្មើអនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

៩-ឯកឧត្តម **ខូស សារឿន** អគ្គលេខាធិការរង មានឋានៈស្មើអនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

១០-ឯកឧត្តម **គង់ កុសល** អគ្គលេខាធិការរង មានឋានៈស្មើអនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

**មាត្រា៣:** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៤:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*នស.រកត.១១១៣.១៣០៥*

លេខ:១២៨១ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

*ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០១៣*

រាជធានីភ្នំពេញ .ថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១៤៩៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៩/៩៤៣ ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០០៩ ស្តីពីការកែសម្រួល និងការធ្វើនិយតភាពការបង្កើតគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១:** តែងតាំងឯកឧត្តម **ឡុង សារាវុធ** ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានឋានៈស្មើ អគ្គនាយក ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល-១៣១១.១៣០៦

លេខ:១២៦៥ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៣

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៥៣

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រតនត្តយាធិបតី ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន ០២រូប :

១. ឯកឧត្តម **ជា សុខុម** មានឋានៈស្មើ រដ្ឋមន្ត្រី
២. ឯកឧត្តម **តូច សុផារ៉ា** មានឋានៈស្មើ អនុរដ្ឋលេខាធិការ។

**មាត្រា ២:** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរណ.១៣១១.១៣០៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខ ១២៧៩ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៩៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងព័ត៌មាន

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងមន្ត្រីរាជការចំនួន ០៣រូប ជាទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើ **អគ្គនាយក** ៖

១- ឯកឧត្តម **សោម សារុន**

២- ឯកឧត្តម **ចាន់ សាវ៉ាត**

៣- ឯកឧត្តម **សុខ សុភា**

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល. ១៣១១. ១៣០៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខ: ១២៦៣ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
**រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ២០១៣**
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ស៊យ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥៥៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ៨៨៦,៨៩ ហិកតា នៅស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ចេញពីដីគម្រប ព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៩០ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ១៥៨២ ខបជ ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបន្ទាយមានជ័យ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សម្រេច

**មាត្រា ១**: ត្រូវបានកាត់ផ្ទៃដីទំហំ ៨៨៦,៨៩ ហិកតា ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ ៨៦៧,៤៩ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១៩,៤០ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ (ផ្លូវ, ប្រឡាយ, អូរ...) នៅភូមិស្វាយ ឃុំថ្មពួក ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកា ដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបន្ទាយមានជ័យ ធ្វើការគ្រប់គ្រង និងប្រទានកម្ម ជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង ១៩០ គ្រួសារ នៅភូមិស្វាយ ឃុំថ្មពួក ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។

**មាត្រា ៣**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបន្ទាយមានជ័យ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងសង្គមនៅក្នុងមូលដ្ឋាន។

**មាត្រា ៤**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ៨ ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ...៥៥៥ អនក.បក... ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០១៣ ស្តីពីការកាត់ដី
ទំហំ ៨៨៦,៨៩ ហិកតា នៅស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ចេញពីដីតម្រូវព្រៃឈើ ឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជន
របស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៩០ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៥៦២ . អនក្រ . បក**

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលអត្រាអាករពិសេសលើទំនិញមួយចំនួន

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញាឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១. នស ចុះថ្ងៃទី២៨ ខែធ្នូឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១.នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៥/០១ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២១ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០
- បានឃើញអនុក្រឹត្យលេខ២៤ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០១ ស្តីពីការកែសម្រួលអត្រាពន្ធគយ និងអាករលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ១២០ អនក្រ.បក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីការកែសម្រួលអត្រាពន្ធគយ និងអាករពិសេសលើទំនិញមួយចំនួន

- បានឃើញអនុក្រឹត្យលេខ៧៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកែប្រែអត្រាពន្ធគយ និងអាករពិសេសលើទំនិញ និងសេវាមួយចំនួន និងអាករបន្ថែមនៃពន្ធគយលើផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ៧៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកែប្រែអត្រាពន្ធគយ និងអាករពិសេសលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ស្តីពីការកែសម្រួលអត្រាអាករពិសេស និងអត្រាអាករនាំចេញលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ១៧៤ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកែសម្រួលអត្រាអាករពិសេស និងអត្រាអាករនាំចេញលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ២៦៩ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការកែសម្រួលអត្រាអាករពិសេស និងអត្រាអាករនាំចេញលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការកែសម្រួលអត្រាអាករពិសេស និងអត្រាអាករនាំចេញលើទំនិញមួយចំនួន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១.-**

ត្រូវបានតម្លើងអត្រាអាករពិសេសពី ២០% ទៅ ៣០% លើមុខទំនិញចំនួន ១៣៣ បន្ទាត់ពន្ធនៃតារាងពន្ធគយកម្ពុជាជាធរមានក្នុងទីតាំងរងលេខ ៨៧០១.២០.១០ ៨៧០១.២០.៩០

៨៧០២.១០.១០ ៨៧០២.១០.៤១ ៨៧០២.១០.៤៩ ៨៧០២.១០.៥០ ៨៧០២.១០.៦០
៨៧០២.១០.៧១ ៨៧០២.១០.៧៩ ៨៧០២.១០.៨១ ៨៧០២.១០.៨៩ ៨៧០២.១០.៩០
៨៧០២.៩០.១២ ៨៧០២.៩០.១៣ ៨៧០២.៩០.១៤ ៨៧០២.៩០.១៩ ៨៧០២.៩០.៩២
៨៧០២.៩០.៩៣ ៨៧០២.៩០.៩៤ ៨៧០២.៩០.៩៥ ៨៧០២.៩០.៩៩ ៨៧០៤.១០.១៣
៨៧០៤.១០.១៤ ៨៧០៤.១០.១៥ ៨៧០៤.១០.១៦ ៨៧០៤.១០.១៧ ៨៧០៤.១០.១៨
៨៧០៤.១០.២៣ ៨៧០៤.១០.២៤ ៨៧០៤.១០.២៥ ៨៧០៤.១០.២៦ ៨៧០៤.១០.២៧
៨៧០៤.១០.២៨ ៨៧០៤.២១.១១ ៨៧០៤.២១.១៩ ៨៧០៤.២១.២១ ៨៧០៤.២១.២៣
៨៧០៤.២១.២៤ ៨៧០៤.២១.២៥ ៨៧០៤.២១.២៩ ៨៧០៤.២២.១១ ៨៧០៤.២២.១៩
៨៧០៤.២២.២១ ៨៧០៤.២២.២៣ ៨៧០៤.២២.២៤ ៨៧០៤.២២.២៥ ៨៧០៤.២២.២៩
៨៧០៤.២២.៣១ ៨៧០៤.២២.៣៩ ៨៧០៤.២២.៤១ ៨៧០៤.២២.៤៣ ៨៧០៤.២២.៤៤
៨៧០៤.២២.៤៥ ៨៧០៤.២២.៥១ ៨៧០៤.២២.៥៩ ៨៧០៤.២៣.១១ ៨៧០៤.២៣.១៩
៨៧០៤.២៣.២១ ៨៧០៤.២៣.២៣ ៨៧០៤.២៣.២៤ ៨៧០៤.២៣.២៥ ៨៧០៤.២៣.២៩
៨៧០៤.២៣.៥១ ៨៧០៤.២៣.៥៩ ៨៧០៤.២៣.៦១ ៨៧០៤.២៣.៦៣ ៨៧០៤.២៣.៦៤
៨៧០៤.២៣.៦៥ ៨៧០៤.២៣.៦៦ ៨៧០៤.២៣.៦៩ ៨៧០៤.២៣.៧១ ៨៧០៤.២៣.៧៩
៨៧០៤.២៣.៨១ ៨៧០៤.២៣.៨៣ ៨៧០៤.២៣.៨៤ ៨៧០៤.២៣.៨៥ ៨៧០៤.២៣.៨៦
៨៧០៤.២៣.៨៩ ៨៧០៤.៣១.១១ ៨៧០៤.៣១.១៩ ៨៧០៤.៣១.២១ ៨៧០៤.៣១.២៣
៨៧០៤.៣១.២៤ ៨៧០៤.៣១.២៥ ៨៧០៤.៣១.២៩ ៨៧០៤.៣២.១១ ៨៧០៤.៣២.១៩

៨៧០៤.៣២.២១ ៨៧០៤.៣២.២៣ ៨៧០៤.៣២.២៤ ៨៧០៤.៣២.២៥ ៨៧០៤.៣២.២៩
៨៧០៤.៣២.៣១ ៨៧០៤.៣២.៣៩ ៨៧០៤.៣២.៤១ ៨៧០៤.៣២.៤៣ ៨៧០៤.៣២.៤៤
៨៧០៤.៣២.៤៥ ៨៧០៤.៣២.៤៦ ៨៧០៤.៣២.៤៩ ៨៧០៤.៣២.៥១ ៨៧០៤.៣២.៥៩
៨៧០៤.៣២.៦១ ៨៧០៤.៣២.៦៣ ៨៧០៤.៣២.៦៤ ៨៧០៤.៣២.៦៥ ៨៧០៤.៣២.៦៩
៨៧០៤.៣២.៧២ ៨៧០៤.៣២.៧៩ ៨៧០៤.៣២.៨១ ៨៧០៤.៣២.៨៣ ៨៧០៤.៣២.៨៤
៨៧០៤.៣២.៨៥ ៨៧០៤.៣២.៨៦ ៨៧០៤.៣២.៨៩ ៨៧០៤.៣២.៩១ ៨៧០៤.៣២.៩២
៨៧០៤.៣២.៩៣ ៨៧០៤.៣២.៩៥ ៨៧០៤.៣២.៩៦ ៨៧០៤.៣២.៩៧ ៨៧០៤.៣២.៩៨
៨៧០៤.៣២.៩៩ ៨៧០៤.៩០.១០ ៨៧០៤.៩០.៩១ ៨៧០៤.៩០.៩២ ៨៧០៤.៩០.៩៣
៨៧០៤.៩០.៩៤ ៨៧០៤.៩០.៩៩ ៨៧០៥.១០.០០ ៨៧០៥.២០.០០ ៨៧០៥.៤០.០០
និង ៨៧០៥.៩០.៩០។

**មាត្រា២.-**

ត្រូវបានតម្លើងអត្រាអាករពិសេសពី ៤៥% ទៅ ៥០% លើមុខទំនិញចំនួន ៨០ បន្ទាត់ពន្ធ នៃតារាងពន្ធគយកម្ពុជាជាធរមានក្នុងទីតាំងវង់លេខ៨៧០៣.១០.១០ ៨៧០៣.១០.៩០ ៨៧០៣.២២.១១
៨៧០៣.២២.១៩ ៨៧០៣.២២.២១ ៨៧០៣.២២.២៩ ៨៧០៣.២២.៩២ ៨៧០៣.២២.៩៩
៨៧០៣.២៣.៤០ ៨៧០៣.២៣.៥១ ៨៧០៣.២៣.៥២ ៨៧០៣.២៣.៥៣ ៨៧០៣.២៣.៥៤
៨៧០៣.២៣.៦១ ៨៧០៣.២៣.៦២ ៨៧០៣.២៣.៦៣ ៨៧០៣.២៣.៦៤ ៨៧០៣.២៣.៧១
៨៧០៣.២៣.៧២ ៨៧០៣.២៣.៧៣ ៨៧០៣.២៣.៧៤ ៨៧០៣.២៣.៩១ ៨៧០៣.២៣.៩២
៨៧០៣.២៣.៩៣ ៨៧០៣.២៣.៩៤ ៨៧០៣.២៤.៤១ ៨៧០៣.២៤.៤៩ ៨៧០៣.២៤.៥១
៨៧០៣.២៤.៥៩ ៨៧០៣.២៤.៧០ ៨៧០៣.២៤.៨១ ៨៧០៣.២៤.៨៩ ៨៧០៣.២៤.៩១
៨៧០៣.២៤.៩៩ ៨៧០៣.៣១.១១ ៨៧០៣.៣១.១៩ ៨៧០៣.៣១.២០ ៨៧០៣.៣១.៤០
៨៧០៣.៣១.៥០ ៨៧០៣.៣១.៨១ ៨៧០៣.៣១.៨៩ ៨៧០៣.៣១.៩១ ៨៧០៣.៣១.៩៩
៨៧០៣.៣២.៤២ ៨៧០៣.៣២.៤៣ ៨៧០៣.៣២.៤៤ ៨៧០៣.៣២.៤៩ ៨៧០៣.៣២.៥២
៨៧០៣.៣២.៥៣ ៨៧០៣.៣២.៥៤ ៨៧០៣.៣២.៥៩ ៨៧០៣.៣២.៦០ ៨៧០៣.៣២.៧១
៨៧០៣.៣២.៧២ ៨៧០៣.៣២.៧៣ ៨៧០៣.៣២.៧៩ ៨៧០៣.៣២.៩២ ៨៧០៣.៣២.៩៣
៨៧០៣.៣២.៩៤ ៨៧០៣.៣២.៩៩ ៨៧០៣.៣៣.៤៣ ៨៧០៣.៣៣.៤៤ ៨៧០៣.៣៣.៤៥
៨៧០៣.៣៣.៤៩ ៨៧០៣.៣៣.៥៣ ៨៧០៣.៣៣.៥៤ ៨៧០៣.៣៣.៥៥ ៨៧០៣.៣៣.៥៩
៨៧០៣.៣៣.៧០ ៨៧០៣.៣៣.៨១ ៨៧០៣.៣៣.៨៩ ៨៧០៣.៣៣.៩១ ៨៧០៣.៣៣.៩៩
៨៧០៣.៩០.១២ ៨៧០៣.៩០.១៣ ៨៧០៣.៩០.១៩ ៨៧០៣.៩០.៥០ ៨៧០៣.៩០.៧០
៨៧០៣.៩០.៨០ និង៨៧០៣.៩០.៩០។

**មាត្រា៣.-**

ត្រូវបានតម្លើងអត្រាអាករពិសេសពី ១៥% ទៅ ២៥% លើមុខទំនិញចំនួន ១០ បន្ទាត់ពន្ធ នៃតារាងពន្ធគយកម្ពុជាជាធរមានក្នុងទីតាំងវង់លេខ ៨៧០៣.២១.១០ ៨៧០៣.២១.២២ ៨៧០៣.២១.២៣
៨៧០៣.២១.២៤ ៨៧០៣.២១.២៩ ៨៧០៣.២១.៣១ ៨៧០៣.២១.៣៩ ៨៧០៣.២១.៩១
៨៧០៣.២១.៩២ និង ៨៧០៣.២១.៩៩។

**មាត្រា៤.-**

ត្រូវបានតម្លើងអត្រាអាករពិសេសពី ០% ទៅ ១០% លើមុខទំនិញចំនួន ០៣ បន្ទាត់ពន្ធ នៃតារាងពន្ធគយកម្ពុជាជាធរមានក្នុងទីតាំងរងលេខ៨៥១៧.១១.០០ ៨៥១៧.១២.០០និង៨៥១៧.១៨.០០។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកចាត់ចែងអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៤ តទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីដើម្បីចុះហត្ថលេខា**

**បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ចម្លងជូន៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- គ្រប់សាលាខេត្តនិងសាលារាជធានី
- ដូចមាត្រា ៦
- រាជកិច្ច

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៦៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើចំណាត់ថ្នាក់ជាទ្រព្យសម្បត្តិរបស់រដ្ឋ នូវទីតាំងដី សម្រាប់ការសាងសង់អគារត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិព្រៃវល្លិ៍

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១២ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ-បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា១.-**

ត្រូវបានកំណត់បរិវេណដី សម្រាប់ធ្វើការសាងសង់អគារត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិព្រៃវល្លិ៍ ដែលមានទីតាំងស្ថិតនៅភូមិអូរ ឃុំថ្មី ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ។

**មាត្រា២.-**

ត្រូវបានធ្វើចំណាត់ថ្នាក់បរិវេណដី ដូចមានបញ្ជាក់ក្នុងប្លង់ឧបសម្ព័ន្ធ ដែលមានផ្ទៃក្រឡាសរុប ៥.៣០ ហិកតា ជាប្រភេទដីមានលក្ខណៈសម្បត្តិជាទ្រព្យសាធារណៈរបស់រដ្ឋ ដែលមានទីតាំងស្ថិតនៅភូមិអូរ ឃុំថ្មី ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ប្រកបដោយរបបគតិយុត្ត ដូចមានចែងក្នុងមាត្រា ១៥, មាត្រា ១៦, មាត្រា ១៧ នៃច្បាប់ភូមិបាល ចុះថ្ងៃទី ៣១ សីហា ឆ្នាំ ២០០១ និងមាននិយាមការដូចខាងក្រោម៖

| ID. | Northing | Easting |
|---|---|---|
| P1 | 1198435.27 | 601709.14 |
| P2 | 1198442.53 | 601638.97 |
| P3 | 1198449.79 | 601568.81 |
| P4 | 1198457.06 | 601498.64 |
| P5 | 1198513.88 | 601490.11 |
| P6 | 1198570.71 | 601481.58 |
| P7 | 1198627.53 | 601473.04 |
| P8 | 1198684.36 | 601464.51 |
| P9 | 1198695.94 | 601531.85 |
| P10 | 1198707.53 | 601599.19 |
| P11 | 1198719.11 | 601666.53 |

**មាត្រា៣.-**

រាល់ការទន្ទ្រានយកដី ការដោះដូរ ការទិញលក់ ឬការផ្ទេរកម្មសិទ្ធិ ការចេញបណ្ណ័សំគាល់សិទ្ធិកាន់កាប់នៃអចលនវត្ថុទាំងឡាយតាមគ្រប់រូបភាពទាំងអស់ ទោះស្របច្បាប់ក៏ដោយ ដែលស្ថិតនៅក្នុងបរិវេណដីបង្កកដូចបានពណ៌នាខាងលើនេះ និងការចេញលិខិតអនុញ្ញាតឱ្យសាងសង់សំណង់ថ្មី ត្រូវបានហាមឃាត់ លើកលែងតែការផ្ទេរកម្មសិទ្ធិសម្រាប់បំរើផលប្រយោជន៍សាធារណៈ ។

រាល់ការបំពានលើបទប្បញ្ញត្តិ ដូចមានចែងខាងលើ អ្នកប្រព្រឹត្តល្មើសនឹងទទួលទណ្ឌកម្មដែលមានចែងនៅក្នុងមាត្រា ២៥៩ នៃច្បាប់ភូមិបាល ចុះថ្ងៃទី ៣១ សីហា ឆ្នាំ ២០០១ ។

**មាត្រា៤.-**

ម្ចាស់កម្មសិទ្ធិ ឬភោគីនៃដីឡូតិ៍ ក្នុងបរិវេណដីដែលនឹងត្រូវផ្ទេរប្រគល់ជូនរដ្ឋ ដើម្បីជាប្រយោជន៍សាធារណៈសម្រាប់ការសាងសង់អគារត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិព្រៃវល្លិ៍ នឹងទទួលបាននូវការទូទាត់សំណងសមរម្យ និងយុត្តិធម៌ ផ្អែកតាមការសិក្សាតម្លៃជំនួស ពីគណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ដោយសារគម្រោងការសាងសង់អគារត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិព្រៃវល្លិ៍ខាងលើនេះ ។

**មាត្រា៥.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងមហាផ្ទៃ, ក្រសួងទេសចរណ៍ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, រដ្ឋមន្ត្រី និងរដ្ឋលេខាធិការទាំងអស់ ដែលមានការពាក់ព័ន្ធ ព្រមទាំងអភិបាលខេត្តស្វាយរៀង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពខ្ពស់តាមភារកិច្ចរៀង១ខ្លួន ។

**មាត្រា៦.-**

អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យជិទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ


CBF
Prey Voir International Border Check Point
CUSTOM&EXCISE
FIELD FARM BELONG TO CUSTOM AND EXISE
X=601709.14
Y=1198435.27
X=601638.97
Y=1198442.53
X=601568.87
Y=1198449.79
X=601498.64
Y=1198457.06
X=601490.11
Y=1198513.88
X=601481.58
Y=1198570.71
X=601473.04
Y=1198627.53
X=601464.51
Y=1198684.36
X=601531.85
Y=1198695.94
X=601666.53
Y=1198719.11
EP: 25+491.76
CAMBODIA GATE
25+492
HOUSE
PREY VOIR CHECK POINT
Prey Voir Internal Revenue Office
PBM4
BM20UD
CUSTOM AND EXCISE
CASINO & HOTEL UNDER CONSTRUCTION
25+400
FREE LAND
ELE: 8.20m
5.2963 ha
To Prese Vil Bokvea CASINO Raod
25+300
MASSAGE 333
Lucky 89. CASINO
LUCKY CASINO 89
25+200
CASINO & HOTEL 333
To 9999 Raod
PT: 25+145.71
N

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៥៦៤ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិ តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
